ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ:.....០៣៣...... ដ.ន.ស./ប្រ.ក. និ.ភ

# ប្រកាស
## ស្តីពី
## បែបបទនិងបរិបទនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន។

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានឃើញអនុក្រឹត្យលេខ២២៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះកំណត់អំពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាពអាជ្ញាបណ្ណ និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្នុងគោលបំណងដើម្បីអនុវត្តអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់។

**ប្រការ២._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- **តំណាងស្របច្បាប់របស់ក្រុមហ៊ុន** សំដៅដល់អគ្គនាយកក្រុមហ៊ុន នាយកក្រុមហ៊ុន ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ឬអភិបាលក្រុមហ៊ុនដែលមានគោត្តនាមនិងនាមត្រូវបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

៣-**វិញ្ញាបនបត្រធានារ៉ាប់រង** សំដៅដល់លិខិតផ្តល់ដោយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤-**វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

៥-**វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ** សំដៅដល់វិញ្ញាបនបត្រស្ថាបត្យករចុះបញ្ជី វិញ្ញាបនបត្រស្ថាបត្យករ គ.ស.ក. Certificate of Registration as an ASEAN ARCHITECT (វិញ្ញាបនបត្រចុះបញ្ជីជាស្ថាបត្យករអាស៊ាន) វិញ្ញាបនបត្រស្ថាបត្យករបរទេសចុះបញ្ជី វិញ្ញាបនបត្រវិស្វករចុះបញ្ជី វិញ្ញាបនបត្រវិស្វករចុះបញ្ជីដំបូង វិញ្ញាបនបត្រវិស្វករអាជីព វិញ្ញាបនបត្រចុះបញ្ជីវិស្វករបរទេស និងវិញ្ញាបនបត្រចុះបញ្ជីវិស្វករអាជីពឆ្នើមបរទេស។

៦-**អាជ្ញាបណ្ណ** សំដៅដល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៧-**អ្នកកាន់អាជ្ញាបណ្ណ** សំដៅដល់អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលបានទទួលសិទ្ធិផ្តល់ដោយអាជ្ញាបណ្ណ និងដែលមានគោត្តនាមនិងនាមឬនាមករណ៍នៅលើអាជ្ញាបណ្ណ។

៨-**អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់** សំដៅដល់ក្រុមការងារនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនដែលមានអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៩-**អ្នកវិជ្ជាជីវៈ** សំដៅដល់ស្ថាបត្យករនិងវិស្វករដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងនាយកបច្ចេកទេសឬអ្នកបច្ចេកទេសនៃក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ។

១០-**ឯកសារបញ្ជាក់បទពិសោធន៍ការងារ** សំដៅដល់កិច្ចសន្យាការងារ លិខិតបញ្ជាក់ ឬឯកសារដទៃទៀតដែលផ្តល់ព័ត៌មានអំពីការងារដែលអ្នកវិជ្ជាជីវៈធ្លាប់បានបំពេញកន្លងមក មានជាអាទិ៍ មុខជំនាញ រយៈពេល ទីកន្លែង អត្តសញ្ញាណរបស់និយោជក។

១១-**ឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែង** សំដៅដល់ទិដ្ឋាការបន្តរយៈពេលស្នាក់នៅបណ្តោះអាសន្នយ៉ាងតិច១២(ដប់ពីរ)ខែ សម្រាប់ផ្តល់ចំពោះជនបរទេសមិនមែនអន្តោប្រវេសន្តជាពាណិជ្ជកររួមមានទិដ្ឋាការប្រភេទ $E1_{EX}$ $E2_{EX}$ $E3_{EX}$ $E_{B}$ ជនបរទេសមិនមែនអន្តោប្រវេសន្ត

ជាអ្នកបច្ចេកទេសជំនាញរួមមានទិដ្ឋាការប្រភេទ $E_T$ និងជនបរទេសមិនមែនអន្តោប្រវេសន្ត ជានិស្សិតរួមមានទិដ្ឋាការប្រភេទ $E_S$។

## ជំពូកទី២

## បែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ

**ប្រការ៣._**

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ មានដូចខាងក្រោម៖

១- ពាក្យស្នើសុំអាជ្ញាបណ្ណ ចំនួន១ច្បាប់

២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ(ថតចម្លង) ចំនួន១ច្បាប់

៣- សញ្ញាបត្រ(ថតចម្លង) ចំនួន១ច្បាប់

៤- ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង) ចំនួន១ច្បាប់

៥- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធ(ថតចម្លង) ចំនួន១ច្បាប់

៦- វិញ្ញាបនបត្រធានារ៉ាប់រងឬឯកសារបញ្ជាក់ការតម្កល់ប្រាក់ នៅធនាគារជាតិនៃកម្ពុជា(ថតចម្លង) ចំនួន១ច្បាប់

៧- លិខិតធានាអះអាងរបស់អ្នកស្នើសុំអាជ្ញាបណ្ណ ចំនួន១ច្បាប់

អ្នកវិជ្ជាជីវៈដែលមានអាជ្ញាបណ្ណសិក្សាគម្រោងប្លង់ អាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់បាន ក្នុងករណីអ្នកវិជ្ជាជីវៈនោះបំពេញលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់។

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១នៃប្រកាសនេះ។

គំរូទម្រង់លិខិតធានាអះអាងរបស់អ្នកស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី២នៃ ប្រកាសនេះ។

**ប្រការ៤._**

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន មានដូចខាងក្រោម៖

ក. ឯកសារពាក់ព័ន្ធនឹងក្រុមហ៊ុន

១- ពាក្យស្នើសុំអាជ្ញាបណ្ណ ចំនួន១ច្បាប់

២- លក្ខន្តិកៈក្រុមហ៊ុន(ថតចម្លង) ចំនួន១ច្បាប់

៣- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម(ថតចម្លង) ចំនួន១ច្បាប់

៤- បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេស ចំនួន១ច្បាប់

៥- វិញ្ញាបនបត្រផានារ៉ាប់រងឬឯកសារបញ្ជាក់ការតម្កល់ប្រាក់
នៅធនាគារជាតិនៃកម្ពុជា(ថតចម្លង) ចំនួន១ច្បាប់

ខ. ឯកសារពាក់ព័ន្ធនឹងអភិបាលរបស់ក្រុមហ៊ុន
អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ(ថតចម្លង) ចំនួន១ច្បាប់

គ. ឯកសារពាក់ព័ន្ធនឹងនាយកបច្ចេកទេស

១- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ(ថតចម្លង) ចំនួន១ច្បាប់

២- សញ្ញាបត្រ(ថតចម្លង) ចំនួន១ច្បាប់

៣- ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង) ចំនួន១ច្បាប់

៤- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ(ថតចម្លង) ចំនួន១ច្បាប់

៥- លិខិតធានាអះអាងរបស់នាយកបច្ចេកទេស ចំនួន១ច្បាប់

ឃ. ឯកសារពាក់ព័ន្ធនឹងអ្នកបច្ចេកទេស

១- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ(ថតចម្លង) ចំនួន១ច្បាប់

២- សញ្ញាបត្រ(ថតចម្លង) ចំនួន១ច្បាប់

៣- ឯកសារបញ្ជាក់បទពិសោធន៍ការងារ(ថតចម្លង) ចំនួន១ច្បាប់

៤- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈ(ថតចម្លង) ចំនួន១ច្បាប់

៥- លិខិតធានាអះអាងរបស់អ្នកបច្ចេកទេស ចំនួន១ច្បាប់

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

គំរូទម្រង់លិខិតធានាអះអាងរបស់តំណាងក្រុមហ៊ុន ជាឧបសម្ព័ន្ធទី៤នៃប្រកាសនេះ។

គំរូទម្រង់លិខិតធានាអះអាងរបស់នាយកបច្ចេកទេស ជាឧបសម្ព័ន្ធទី៥នៃប្រកាសនេះ។

គំរូទម្រង់លិខិតធានាអះអាងរបស់អ្នកបច្ចេកទេស ជាឧបសម្ព័ន្ធទី៦នៃប្រកាសនេះ។

គំរូទម្រង់បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេស ជាឧបសម្ព័ន្ធទី៧នៃប្រកាសនេះ។

**ប្រការ៥.**

ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈ ត្រូវបង្ហាញបទពិសោធន៍ការងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនសិក្សាគម្រោងប្លង់ឬក្រុមហ៊ុនសាងសង់ អ្នកសិក្សាគម្រោងប្លង់ឬរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ នាយកគម្រោង អ្នកគ្រប់គ្រងគម្រោង អ្នកគ្រប់គ្រងការដ្ឋានសំណង់ ឬប្រធានការដ្ឋានសំណង់។

សម្រាប់សំណុំឯកសារស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១និងអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១ ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់នាយកបច្ចេកទេសដែលមានមុខជំនាញផ្នែកវិស្វកម្មគ្រឿងផ្គុំ ត្រូវបង្ហាញបទពិសោធន៍ការងារក្នុងគម្រោងសាងសង់អគារខ្ពស់ចំនួនយ៉ាងតិច១(មួយ)គម្រោង សម្រាប់នាយកបច្ចេកទេសដែលមានសញ្ញាបត្របណ្ឌិត យ៉ាងតិច៣(បី)គម្រោង សម្រាប់នាយកបច្ចេកទេសដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬយ៉ាងតិច៧(ប្រាំពីរ)គម្រោង សម្រាប់នាយកបច្ចេកទេសដែលមានសញ្ញាបត្របរិញ្ញាបត្រ។

សម្រាប់សំណុំឯកសារស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១និងអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១ ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់អ្នកបច្ចេកទេសដែលមានមុខជំនាញផ្នែកបច្ចេកទេសភូគព្ភសាស្ត្រ ត្រូវបង្ហាញបទពិសោធន៍ការងារក្នុងគម្រោងសាងសង់សំណង់ដែលមានជាន់ក្រោមដីក្នុងជម្រៅជ្រៅជាង១០(ដប់)ម៉ែត្រ ចំនួនយ៉ាងតិច១(មួយ)គម្រោង សម្រាប់អ្នកបច្ចេកទេសដែលមានសញ្ញាបត្របណ្ឌិត យ៉ាងតិច៣(បី)គម្រោង សម្រាប់អ្នកបច្ចេកទេសដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬយ៉ាងតិច៧(ប្រាំពីរ)គម្រោង សម្រាប់អ្នកបច្ចេកទេសដែលមានសញ្ញាបត្របរិញ្ញាបត្រ។

**ប្រការ៦.**_

ការគណនារយៈពេលនៃបទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈ ត្រូវអនុវត្តដូចខាងក្រោម៖

- បទពិសោធន៍ការងាររយៈពេល៧(ប្រាំពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របណ្ឌិត និងបទពិសោធន៍ការងាររយៈពេល១២(ដប់ពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានតម្លៃសមមូលនឹងបទពិសោធន៍ការងាររយៈពេល២០(ម្ភៃ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រ។
- បទពិសោធន៍ការងាររយៈពេល៣(បី)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របណ្ឌិត និងបទពិសោធន៍ការងាររយៈពេល៧(ប្រាំពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានតម្លៃសមមូលនឹងបទពិសោធន៍ការងាររយៈពេល១៥(ដប់ប្រាំ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រ។
- បទពិសោធន៍ការងាររយៈពេល២(ពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របណ្ឌិត និងបទពិសោធន៍ការងាររយៈពេល៥(ប្រាំ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានតម្លៃសមមូលនឹងបទពិសោធន៍ការងាររយៈពេល១០(ដប់)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រ។

- បទពិសោធន៍ការងាររយៈពេល១(មួយ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របណ្ឌិត និង បទពិសោធន៍ការងាររយៈពេល៣(បី)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ មានតម្លៃស្មើនឹងបទពិសោធន៍ការងាររយៈពេល៧(ប្រាំពីរ)ឆ្នាំរបស់អ្នកវិជ្ជាជីវៈដែលមានសញ្ញាបត្របរិញ្ញាបត្រ។

ការងារទាំងឡាយដែលអ្នកវិជ្ជាជីវៈបានបំពេញមុនកាលបរិច្ឆេទចេញសញ្ញាបត្របរិញ្ញាបត្ររបស់ខ្លួន មិនត្រូវបានរាប់បញ្ចូលសម្រាប់គណនារយៈពេលនៃបទពិសោធន៍ការងារឡើយ។

រយៈពេលនៃបទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈ ត្រូវគណនាដោយបូកបញ្ចូលរយៈពេលបំពេញការងារដែលមានចែងក្នុងឯកសារបញ្ជាក់បទពិសោធន៍ការងារទាំងអស់។

ក្នុងករណីអ្នកវិជ្ជាជីវៈបានបំពេញការងារពេញម៉ោង រយៈពេលនៃបទពិសោធន៍ការងារត្រូវគណនាជាឆ្នាំដូចមានចែងក្នុងឯកសារបញ្ជាក់បទពិសោធន៍ការងារ។

ក្នុងករណីអ្នកវិជ្ជាជីវៈបានបំពេញការងារក្រៅម៉ោង រយៈពេលនៃបទពិសោធន៍ការងារត្រូវគិតជាឆ្នាំ ដោយក្នុងរយៈពេល១(មួយ)ឆ្នាំ អ្នកវិជ្ជាជីវៈនោះត្រូវបំពេញការងារឱ្យបានយ៉ាងតិច២០០០(ពីរពាន់)ម៉ោង។

**ប្រការ៧._**

តំណាងស្របច្បាប់របស់ក្រុមហ៊ុន និងអ្នកវិជ្ជាជីវៈដែលស្នើសុំអាជ្ញាបណ្ណ ត្រូវចុះហត្ថលេខាដោយផ្ទាល់លើពាក្យស្នើសុំអាជ្ញាបណ្ណ។

រាល់ឯកសារនៅក្នុងសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ត្រូវធ្វើជាភាសាខ្មែរ។ រាល់ឯកសារជាភាសាបរទេស ត្រូវបកប្រែជាភាសាខ្មែរដោយមានការបញ្ជាក់ពីសារការី។

រាល់ឯកសារថតចម្លងត្រូវធ្វើនីត្យានុកូលកម្មដោយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ ឬដោយសារការី។

សញ្ញាបត្រចេញដោយគ្រឹះស្ថានឧត្តមសិក្សានៅបរទេស ត្រូវមានការបញ្ជាក់ទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៨._**

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ត្រូវដាក់នៅច្រកចេញចូលតែមួយ។

ច្រកចេញចូលតែមួយត្រូវត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណនៅក្នុងថ្ងៃដាក់ពាក្យស្នើសុំ។

**ប្រការ៩._**

ក្នុងករណីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មានគ្រប់ចំនួននិងត្រឹមត្រូវផ្នែកទម្រង់ ច្រកចេញចូលតែមួយ ត្រូវអនុវត្តដូចខាងក្រោម៖

១- ចុះលេខនិងកាលបរិច្ឆេទចូលក្នុងសៀវភៅចុះលេខចូលរបស់ច្រកចេញចូលតែមួយ និងចម្លងលេខនិងកាលបរិច្ឆេទលើពាក្យស្នើសុំអាជ្ញាបណ្ណ។

២- រៀបចំបង្កាន់ដៃទទួលពាក្យស្នើសុំដោយមានលេខនិងកាលបរិច្ឆេទចូល និងហត្ថលេខារបស់មន្ត្រីទទួលបន្ទុក។

៣- ប្រគល់ច្បាប់ដើមនៃបង្កាន់ដៃទទួលពាក្យស្នើសុំដែលមានចុះលេខនិងកាលបរិច្ឆេទចូលជូនទៅម្ចាស់សំណើ នៅក្នុងថ្ងៃពិនិត្យសំណុំឯកសារស្នើសុំនោះ។

៤- ថតចម្លងសំណុំឯកសារស្នើសុំអាជ្ញាបណ្ណចំនួន២(ពីរ)ច្បាប់។

**ប្រការ១០._**

ក្នុងករណីពិនិត្យឃើញថាសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មិនគ្រប់ចំនួនឬមិនត្រឹមត្រូវផ្នែកទម្រង់ មន្ត្រីច្រកចេញចូលតែមួយត្រូវអនុវត្តដូចខាងក្រោម៖

១- បំពេញឱ្យបានច្បាស់លាស់លើតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអំពីការខ្វះឯកសារឬភាពមិនត្រឹមត្រូវនៃឯកសារ។

២- ចុះកាលបរិច្ឆេទ ហត្ថលេខា និងឈ្មោះរបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យសំណុំឯកសារលើតារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំដែលបំពេញរួច។

៣- ប្រគល់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំដែលបានបំពេញ ចុះកាលបរិច្ឆេទ ហត្ថលេខា និងឈ្មោះរបស់មន្ត្រីទទួលបន្ទុកត្រួតពិនិត្យសំណុំឯកសាររួច ជូនទៅម្ចាស់សំណើនៅក្នុងថ្ងៃពិនិត្យសំណុំឯកសារស្នើសុំនោះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី៨នៃប្រកាសនេះ។

គំរូទម្រង់តារាងត្រួតពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី៩នៃប្រកាសនេះ។

**ប្រការ១១._**

ការពិនិត្យនិងសម្រេចលើសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មានរយៈពេលយ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ តាមបរិបថដូចខាងក្រោម៖

១- ច្រកចេញចូលតែមួយត្រូវបញ្ជូនសំណុំឯកសារស្នើសុំទៅអគ្គនាយកដ្ឋានសំណង់ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំ។

២- អគ្គនាយកដ្ឋានសំណង់ដែលមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការ ត្រូវធ្វើកំណត់បង្ហាញស្ដីពីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ដោយមានភ្ជាប់សេចក្ដីព្រាងអាជ្ញាបណ្ណ ក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីច្រកចេញចូលតែមួយ។

៣- កំណត់បង្ហាញស្ដីពីសំណុំឯកសារស្នើសុំអាជ្ញាបណ្ណនេះ ត្រូវដាក់ឆ្លងថ្នាក់ដឹកនាំតាមឋានានុក្រមដើម្បីទទួលមតិយោបល់និងការសម្រេចរបស់ក្រសួង ក្នុងរយៈពេលយ៉ាងយូរ៦(ប្រាំមួយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីអគ្គនាយកដ្ឋានសំណង់។

៤- ច្រកចេញចូលតែមួយត្រូវចាត់ចែងចុះលេខ កាលបរិច្ឆេទ និងបោះត្រាលើសេចក្ដីព្រាងអាជ្ញាបណ្ណ ដើម្បីប្រគល់ជូនម្ចាស់សំណើ ក្នុងរយៈពេលយ៉ាងយូរ២(ពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានការសម្រេចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១២._**

ក្នុងករណីអគ្គនាយកដ្ឋានសំណង់ពិនិត្យឃើញថា សំណុំឯកសារស្នើសុំអាជ្ញាបណ្ណមិនត្រឹមត្រូវ ត្រូវអនុវត្តដូចខាងក្រោម៖

១- អគ្គនាយកដ្ឋានសំណង់ដែលមាននាយកដ្ឋានស្រាវជ្រាវបច្ចេកទេសសំណង់ជាសេនាធិការ ត្រូវធ្វើលិខិតជូនដំណឹងទៅម្ចាស់សំណើដើម្បីកែសម្រួលឬបំពេញបន្ថែម និងបញ្ជូនទៅច្រកចេញចូលតែមួយក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណុំឯកសារស្នើសុំពីច្រកចេញចូលតែមួយ។

២- ច្រកចេញចូលតែមួយ ត្រូវអញ្ជើញម្ចាស់សំណើមកទទួលយកលិខិតជូនដំណឹងអំពីការតម្រូវឱ្យកែសម្រួលឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ក្នុងរយៈពេលយ៉ាងយូរ១(មួយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីពេលទទួលបានលិខិតនោះពីអគ្គនាយកដ្ឋានសំណង់។

រយៈពេលនៃការកែសម្រួលឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ មិនរាប់បញ្ចូលក្នុងបរិបថនៃការពិនិត្យនិងសម្រេចផ្ដល់អាជ្ញាបណ្ណឡើយ។ បរិបថនៃការពិនិត្យនិងសម្រេចផ្ដល់អាជ្ញាបណ្ណក្នុងករណីមានការកែសម្រួលឬបំពេញបន្ថែមសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ ត្រូវចាប់រាប់ជាថ្មីឡើងវិញ គិតចាប់ពីថ្ងៃច្រកចេញចូលតែមួយចេញបង្កាន់ដៃទទួលសំណុំឯកសារដែលបានកែសម្រួលឬបំពេញបន្ថែមនោះ។

**ប្រការ១៣._**

ប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណដែលអាចផ្តល់ជូនអ្នកវិជ្ជាជីវៈ មានដូចខាងក្រោម៖

១- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត៣។

២- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត៣។

៣- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត៣ មុខជំនាញមេកានិក។

៤- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត៣ មុខជំនាញអគ្គិសនី។

៥- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត៣ មុខជំនាញទឹក។

គំរូទម្រង់អាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១០នៃប្រកាសនេះ។

ប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណដែលអាចផ្តល់ជូនក្រុមហ៊ុន មានដូចខាងក្រោម៖

១- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត១។

២- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅកម្រិត២។

៣- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត១។

៤- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្មកម្រិត២។

៥- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១។

៦- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត២។

៧- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត១។

៨- អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹកកម្រិត២។

គំរូទម្រង់អាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១១នៃប្រកាសនេះ។

## ជំពូកទី៣

## បែបបទនិងបរិបទនៃការជូនដំណឹង

**ប្រការ១៤._**

អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីមានការផ្លាស់ប្តូរស្ថានភាពទាំងឡាយនៅក្នុងពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

គំរូទម្រង់លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១២នៃប្រកាសនេះ។

**ប្រការ១៥._**

អ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីដូចខាងក្រោម៖

១- ការប្តូរអភិបាលក្រុមហ៊ុន។

២- ការប្តូរលក្ខន្តិកៈក្រុមហ៊ុន។

៣- ការប្តូរទីតាំងទីស្នាក់ការប្រកបអាជីវកម្ម។

៤- ការប្តូរលេខទូរស័ព្ទនិងអ៊ីមែលសម្រាប់ទំនាក់ទំនង។

៥- ការប្តូរវិញ្ញាបនបត្រធានារ៉ាប់រង។

៦- ការប្តូរចំនួនទឹកប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា។

ក្នុងករណីប្តូរអភិបាលក្រុមហ៊ុន ប្តូរលក្ខន្តិកៈក្រុមហ៊ុន ប្តូរវិញ្ញាបនបត្រធានារ៉ាប់រង និងប្តូរចំនួនទឹកប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់ក្រុមហ៊ុន ត្រូវមានភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

គំរូទម្រង់លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរស្ថានភាពរបស់អ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១៣នៃប្រកាសនេះ។

## ជំពូកទី៤

## បែបបទនិងបរិបថនៃការប្តូរនាយកបច្ចេកទេស និងអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន

**ប្រការ១៦._**

សំណុំឯកសារស្នើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសក្រុមហ៊ុន មានដូចខាងក្រោម៖

១- ពាក្យស្នើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេស ចំនួន១ច្បាប់

២- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននិងទិដ្ឋាការ របស់នាយកបច្ចេកទេសថ្មីនិង/ឬអ្នកបច្ចេកទេសថ្មី (ថតចម្លង) ចំនួន១ច្បាប់

៣- សញ្ញាបត្ររបស់នាយកបច្ចេកទេសថ្មីនិង/ឬអ្នកបច្ចេកទេសថ្មី (ថតចម្លង) ចំនួន១ច្បាប់

៤- ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់នាយកបច្ចេកទេសថ្មីនិង/ឬ អ្នកបច្ចេកទេសថ្មី ចំនួន១ច្បាប់

៥- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីនៅគណៈវិជ្ជាជីវៈរបស់

នាយកបច្ចេកទេសថ្មីនិង/ឬអ្នកបច្ចេកទេសថ្មី (ថតចម្លង) ចំនួន១ច្បាប់

៦- លិខិតធានាអះអាងរបស់នាយកបច្ចេកទេសថ្មីនិង/ឬអ្នកបច្ចេកទេសថ្មី ចំនួន១ច្បាប់

៧- សន្លឹកអាជ្ញាបណ្ណចាស់ (ករណីសុំប្តូរនាយកបច្ចេកទេសថ្មី) ចំនួន១ច្បាប់

គំរូទម្រង់ពាក្យស្នើសុំប្តូរនាយកបច្ចេកទេសនិង/ឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១៤នៃប្រកាសនេះ។

**ប្រការ១៧._**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញលិខិតជូនដំណឹងទៅអ្នកកាន់អាជ្ញាបណ្ណ ដោយមានភ្ជាប់នូវសន្លឹកអាជ្ញាបណ្ណថ្មី ក្នុងករណីនាយកបច្ចេកទេសថ្មីរបស់ក្រុមហ៊ុន បានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញលិខិតជូនដំណឹងទៅអ្នកកាន់អាជ្ញាបណ្ណ ក្នុងករណីអ្នកបច្ចេកទេសថ្មីរបស់ក្រុមហ៊ុនបានបំពេញគ្រប់លក្ខខណ្ឌដែលបានកំណត់។

សន្លឹកអាជ្ញាបណ្ណថ្មី ត្រូវកត់ត្រាកាលបរិច្ឆេទផុតសុពលភាពរបស់អាជ្ញាបណ្ណចាស់ដែលត្រូវប្តូរ។

សន្លឹកអាជ្ញាបណ្ណចាស់ដែលត្រូវបានប្តូរ ត្រូវបោះត្រាមោឃៈ។

ទម្រង់នៃឯកសារនៅក្នុងសំណុំឯកសារស្នើសុំអាជ្ញាបណ្ណ និងនីតិវិធីនៃការពិនិត្យសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំប្តូរនាយកបច្ចេកទេស និងអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន។

## ជំពូកទី៥

## បែបបទនិងបរិបទនៃការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី

**ប្រការ១៨._**

អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ អាចដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីដូចខាងក្រោមៈ

១- ការបាត់បង់ ការរហែក ឬការខូចសន្លឹកអាជ្ញាបណ្ណ។

២- ការប្តូរគោត្តនាមនិងនាមរបស់អ្នកវិជ្ជាជីវៈ។

៣- ការប្តូរអាសយដ្ឋានការិយាល័យថ្មី។

**ប្រការ១៩.**_

អ្នកកាន់អាជ្ញាបណ្ណជាក្រុមហ៊ុន អាចដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងករណីដូចខាងក្រោម៖

១- សន្លឹកអាជ្ញាបណ្ណបានបាត់បង់ រហែក ឬខូច។

២- ការប្តូរនាមករណ៍ក្រុមហ៊ុន។

៣- ការប្តូរទីស្នាក់ការរបស់ក្រុមហ៊ុន។

៤- ការប្តូរប្រធានក្រុមហ៊ុន។

**ប្រការ២០.**_

សំណុំឯកសារស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី មានដូចខាងក្រោម៖

១- ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី ចំនួន១ច្បាប់

២- ពាក្យបណ្តឹងអំពីការបាត់បង់អាជ្ញាបណ្ណ (ថតចម្លង) ឬ សន្លឹកអាជ្ញាបណ្ណដែលរហែកឬខូច ឬឯកសារបញ្ជាក់អំពី ការផ្លាស់ប្តូរស្ថានភាពដែលមានចែងនៅក្នុងអាជ្ញាបណ្ណពាក់ព័ន្ធ នឹងអ្នកកាន់អាជ្ញាបណ្ណ ចំនួន១ច្បាប់

ពាក្យបណ្តឹងអំពីការបាត់បង់អាជ្ញាបណ្ណ ត្រូវមានការបញ្ជាក់របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អំពីការទទួលពាក្យបណ្តឹង។

គំរូទម្រង់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១៥នៃប្រកាសនេះ។

គំរូទម្រង់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១៦នៃប្រកាសនេះ។

**ប្រការ២១.**_

សន្លឹកអាជ្ញាបណ្ណថ្មី ត្រូវកត់ត្រាកាលបរិច្ឆេទផុតសុពលភាពរបស់អាជ្ញាបណ្ណចាស់ដែលត្រូវប្តូរ។

អ្នកកាន់អាជ្ញាបណ្ណ ត្រូវយកសន្លឹកអាជ្ញាបណ្ណចាស់មកប្តូរយកសន្លឹកអាជ្ញាបណ្ណថ្មី លើកលែងតែ ករណីបាត់បង់អាជ្ញាបណ្ណ។

សន្លឹកអាជ្ញាបណ្ណចាស់ដែលត្រូវបានប្តូរ ត្រូវបោះត្រាមោឃៈ។

នីតិវិធីនៃការពិនិត្យនិងសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មី។

## ជំពូកទី៦

## បែបបទនិងបរិបទនៃការបញ្ចប់សុពលភាពអាជ្ញាបណ្ណ

**ប្រការ២២._**

សំណុំឯកសារស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណ មានដូចខាងក្រោម៖

១- ពាក្យស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណ ចំនួន១ច្បាប់

២- សន្លឹកអាជ្ញាបណ្ណ ឬពាក្យបណ្តឹងអំពីការបាត់បង់ អាជ្ញាបណ្ណ ឬសន្លឹកអាជ្ញាបណ្ណដែលរហែកឬខូច ចំនួន១ច្បាប់

ពាក្យបណ្តឹងអំពីការបាត់បង់អាជ្ញាបណ្ណត្រូវមានការបញ្ជាក់របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អំពីការទទួលពាក្យបណ្តឹង។

គំរូទម្រង់ពាក្យស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១៧នៃប្រកាសនេះ។

គំរូទម្រង់ពាក្យស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី១៨នៃប្រកាសនេះ។

**ប្រការ២៣._**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបញ្ចប់សុពលភាពអាជ្ញាបណ្ណដោយប្រកាស។ សន្លឹកអាជ្ញាបណ្ណដែលត្រូវបានបញ្ចប់សុពលភាព ត្រូវបោះត្រាមោឃៈ។

នីតិវិធីនៃការពិនិត្យនិងសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបញ្ចប់សុពលភាពអាជ្ញាបណ្ណ។

## ជំពូកទី៧

## បែបបទនិងបរិបទនៃការបន្តសុពលភាពអាជ្ញាបណ្ណ

**ប្រការ២៤._**

សំណុំឯកសារស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ មានដូចខាងក្រោម៖

១- ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ចំនួន១ច្បាប់

២- បណ្ណប៉ាតង់ប្រចាំឆ្នាំចុងក្រោយ(ថតចម្លង) ចំនួន១ច្បាប់

៣- របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំចុងក្រោយ(ថតចម្លង) ចំនួន១ច្បាប់

ក្នុងករណីមានការកែប្រែឯកសារណាមួយនៃសំណុំឯកសារសម្រាប់ស្នើសុំអាជ្ញាបណ្ណលើកដំបូង និង/ឬសំណុំឯកសារសម្រាប់ស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណបន្តបន្ទាប់ សំណុំឯកសារស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ត្រូវមានបន្ថែមឯកសារថ្មីស្របតាមការកែប្រែនោះ។

គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី១៩នៃប្រកាសនេះ។

គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី២០នៃប្រកាសនេះ។

គំរូទម្រង់របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាបណ្ណជាអ្នកវិជ្ជាជីវៈ ជាឧបសម្ព័ន្ធទី២១នៃប្រកាសនេះ។

គំរូទម្រង់របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់អ្នកកាន់អាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ជាឧបសម្ព័ន្ធទី២២នៃប្រកាសនេះ។

**ប្រការ២៥._**

ពាក្យស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណ ត្រូវដាក់នៅច្រកចេញចូលតែមួយក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃមុនកាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបន្តសុពលអាជ្ញាបណ្ណដោយប្រកាស ដោយមានភ្ជាប់សន្លឹកអាជ្ញាបណ្ណថ្មី។ សន្លឹកអាជ្ញាបណ្ណថ្មីត្រូវរក្សាលេខអាជ្ញាបណ្ណចាស់ កាលបរិច្ឆេទនៃការផ្តល់អាជ្ញាបណ្ណដំបូង និងកំណត់កាលបរិច្ឆេទផុតសុពលភាពថ្មី។

នីតិវិធីនៃការពិនិត្យនិងសម្រេចលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការស្នើសុំបន្តសុពលភាពនៃអាជ្ញាបណ្ណ។

## ជំពូកទី៨

## បែបបទសម្រាប់អ្នកវិជ្ជាជីវៈនិងក្រុមហ៊ុនសញ្ជាតិបរទេស

**ប្រការ២៦._**

សំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈសញ្ជាតិបរទេស ត្រូវមានបន្ថែមបណ្ណការងារ និងឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២៧._**

សម្រាប់ក្រុមហ៊ុនសញ្ជាតិបរទេសដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ដែលស្នើសុំអាជ្ញាបណ្ណនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតប្រគល់សិទ្ធិជាភ្នាក់ងារតំណាងដែលចុះហត្ថលេខាដោយប្រធានក្រុមហ៊ុន។

សម្រាប់នាយកបច្ចេកទេសនិងអ្នកបច្ចេកទេសសញ្ជាតិបរទេស សំណុំឯកសារស្នើសុំអាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន ត្រូវមានបន្ថែមបណ្ណការងារ និងឯកសារបញ្ជាក់សិទ្ធិស្នាក់នៅរយៈពេលវែងនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់នាយកបច្ចេកទេសឬអ្នកបច្ចេកទេសនោះ។

**ប្រការ២៨._**

ឯកសារបញ្ជាក់បទពិសោធន៍ការងាររបស់អ្នកវិជ្ជាជីវៈសញ្ជាតិបរទេស ត្រូវមានការបញ្ជាក់ទទួលស្គាល់ដោយស្ថានទូតឬស្ថានតំណាងបរទេសពាក់ព័ន្ធប្រចាំព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩

## ការប្តឹងតវ៉ា

**ប្រការ២៩._**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការប្តូរនាយកបច្ចេកទេស និង/ឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន ការបញ្ចប់សុពលភាពអាជ្ញាបណ្ណ និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ មានសិទ្ធិប្តឹងតវ៉ាទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬទៅតុលាការតាមនីតិវិធីជាធរមាន។

## ជំពូកទី១០

## អន្តរប្បញ្ញត្តិ

**ប្រការ៣០._**

នាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនដែលមានវិញ្ញាបនបត្រសិក្សាគម្រោងប្លង់ឬវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្ម អាចបំពេញមុខងារជានាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុននោះ ដើម្បីបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់បាន ក្នុងករណីនាយកបច្ចេកទេសឬអ្នកបច្ចេកទេសនោះ បំពេញលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់។

## ជំពូកទី១១

## អវសានប្បញ្ញត្តិ

**ប្រការ៣១._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣២._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "**ដើម្បីជូនជ្រាប**"
- ដូចប្រការ៣២ "**ដើម្បីមុខការ**"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបែបបទនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់អ្នកវិជ្ជាជីវៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ ______________________ ភេទ ____ អាយុ ___ ឆ្នាំ សញ្ជាតិ _______ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ______________________ផុតកំណត់ _____________ មានការិយាល័យស្ថិតនៅផ្ទះ/អគារលេខ _____________ ផ្លូវ____________________ ភូមិ _________________ ឃុំ/ សង្កាត់ ______________ ក្រុង/ស្រុក/ខណ្ឌ ________________ រាជធានី/ខេត្ត ______________ អ៊ីមែល ______________________________ លេខទូរស័ព្ទ ____________________

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**កម្មវត្ថុ៖** សំណើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ________________________________ កម្រិត ____

**យោង៖** ប្រកាសលេខ________ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី____ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបែបបទនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/ នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ខ្ញុំបាទ/ នាងខ្ញុំបានបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់ ដើម្បីប្រកបវិជ្ជាជីវៈត្រួតពិនិត្យនិងបញ្ជាក់សំណង់ ______________________ កម្រិត _____។

ខ្ញុំបាទ/ នាងខ្ញុំសូមសន្យាអនុវត្តការងារឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់និងបទដ្ឋានគតិយុត្តដទៃទៀត ព្រមទាំងបទដ្ឋានបច្ចេកទេសនិងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

ថ្ងៃ ____________ ខែ ______ ឆ្នាំ__________ ព.ស. ____

ធ្វើនៅ __________________ ថ្ងៃទី_____ខែ_______ ឆ្នាំ ______

**ហត្ថលេខានិងឈ្មោះ**

ឧបសម្ព័ន្ធទី២នៃប្រកាសលេខ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតធានាអះអាងរបស់អ្នកស្នើសុំអាជ្ញាបណ្ណសម្រាប់អ្នកវិជ្ជាជីវៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតធានាអះអាង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ____________ ភេទ ____ អាយុ ______ ឆ្នាំ សញ្ជាតិ ____________ ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ ______ ផ្លូវ ____________ ឃុំ/សង្កាត់ __________ ក្រុង/ស្រុក/ខណ្ឌ ______________ រាជធានី/ខេត្ត ____________ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ____________________ ផុតកំណត់ថ្ងៃទី _____ ខែ _____ ឆ្នាំ ______ សូមអះអាងថា ក្នុងពេលអនុវត្តមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ខ្ញុំបាទ/នាងខ្ញុំនឹងៈ

១- គោរពច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- គោរពបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

៣- បំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤- មិនបំពេញមុខងារជានាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនណាមួយឡើយ។

៥- គោរពតាមគោលការណ៍ណែនាំនិងចូលរួមវគ្គបណ្តុះបណ្តាលអំពីការអនុវត្តការងារតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ថ្ងៃ ____________ ខែ ______ ឆ្នាំ ___________ ព.ស. ___

ធ្វើនៅ __________ ថ្ងៃទី _____ ខែ _______ ឆ្នាំ _______

**ហត្ថលេខានិងឈ្មោះ**

ឧបសម្ព័ន្ធទី៣នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់សម្រាប់ក្រុមហ៊ុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៖៧

**ពាក្យស្នើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ____________________ ភេទ ______ អាយុ ____ ឆ្នាំ សញ្ជាតិ ________ មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ____________________________ ផុតកំណត់ ____________________________
ជាតំណាងក្រុមហ៊ុន ____________________________________________________________________________
ទីស្នាក់ការ ផ្ទះ/អគារលេខ __________________________ ផ្លូវ _____________ ឃុំ/សង្កាត់ _____________ ក្រុង/ស្រុក/ខណ្ឌ ____________ រាជធានី/ខេត្ត _______________ អ៊ីមែល _______________ លេខទូរស័ព្ទ _____________

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**<u>កម្មវត្ថុ</u>៖** សំណើសុំអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ ______________________________________ កម្រិត ____

**<u>យោង</u>៖** ប្រកាសលេខ ________ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ___ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រុមហ៊ុនយើងខ្ញុំបានបំពេញលក្ខខណ្ឌដែលច្បាប់បានកំណត់ និងអាចប្រកបអាជីវកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់ ____________________________________________ កម្រិត ____ បាន។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាអនុវត្តការងារឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់និងបទដ្ឋានគតិយុត្តដទៃទៀត ព្រមទាំងបទដ្ឋានបច្ចេកទេសនិងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

សូមគោរពជូនភ្ជាប់ឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ _____________ ខែ ______ ឆ្នាំ ___________ ព.ស. ___

ធ្វើនៅ _______________ ថ្ងៃទី _____ ខែ _______ ឆ្នាំ _______

**ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន**

ឧបសម្ព័ន្ធទី៤នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតធានាអះអាងរបស់តំណាងក្រុមហ៊ុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៛៧

## លិខិតធានាអះអាង

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ ______________________ ភេទ ____ អាយុ ______ ឆ្នាំ សញ្ជាតិ ____________ ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ _______ ផ្លូវ ____________ ឃុំ/ សង្កាត់ __________ ក្រុង/ ស្រុក/ ខណ្ឌ ______________ រាជធានី/ ខេត្ត ______________ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ ______________ ផុតកំណត់ ថ្ងៃទី ____ ខែ ________ ឆ្នាំ ______ ជាតំណាងក្រុមហ៊ុន ______________________________________ សូមអះអាងថា នៅក្នុងការអនុវត្តមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ក្រុមហ៊ុនយើងខ្ញុំនឹង៖

១- គោរពច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- គោរពបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

៣- បំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤- គោរពតាមគោលការណ៍ណែនាំនិងចាត់នាយកបច្ចេកទេសនិង/ ឬអ្នកបច្ចេកទេសមកចូលរួមវគ្គបណ្តុះបណ្តាលអំពីការអនុវត្តការងារតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ថ្ងៃ ____________ ខែ ______ ឆ្នាំ ___________ ព.ស. ___

ធ្វើនៅ ___________ ថ្ងៃទី _____ ខែ _______ ឆ្នាំ _______

**ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន**

ឧបសម្ព័ន្ធទី៥នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតធានាអះអាងរបស់នាយកបច្ចេកទេស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**លិខិតធានាអះអាង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ______________________ ភេទ____ អាយុ______ឆ្នាំ សញ្ជាតិ__________ ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ______ ផ្លូវ__________ ឃុំ/សង្កាត់_________ ក្រុង/ស្រុក/ខណ្ឌ__________ រាជធានី/ខេត្ត____________អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ____________ ផុតកំណត់ ថ្ងៃទី_____ ខែ________ឆ្នាំ______ សូមអះអាងថា ខ្ញុំបាទ/នាងខ្ញុំបានយល់ព្រមទទួលបំពេញមុខងារជានាយកបច្ចេកទេសរបស់ក្រុមហ៊ុន_______________________________________ ចាប់ពីថ្ងៃទី____ ខែ______ ឆ្នាំ______ តទៅ។

ក្នុងពេលអនុវត្តមុខងារជានាយកបច្ចេកទេស ខ្ញុំបាទ/នាងខ្ញុំនឹងៈ

១- គោរពច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- គោរពបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

៣- បំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤- មិនបំពេញមុខងារជានាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនផ្សេងទៀតឡើយ។

៥- គោរពតាមគោលការណ៍ណែនាំនិងចូលរួមវគ្គបណ្តុះបណ្តាលអំពីការអនុវត្តការងារតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ថ្ងៃ____________ ខែ ______ ឆ្នាំ__________ព.ស. ___

ធ្វើនៅ__________ថ្ងៃទី_____ខែ_______ឆ្នាំ _______

**ហត្ថលេខានិងឈ្មោះ**

បានឃើញនិងឯកភាព

ថ្ងៃ____________ ខែ ______ ឆ្នាំ__________ព.ស. ___

ធ្វើនៅ__________________ថ្ងៃទី_____ខែ_______ឆ្នាំ _______

**ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន**

ឧបសម្ព័ន្ធទី៦នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់លិខិតធានាអះអាងរបស់អ្នកបច្ចេកទេស

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៕៤

**លិខិតធានាអះអាង**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ____________________ ភេទ ____ អាយុ ______ ឆ្នាំ សញ្ជាតិ __________ ទីលំនៅអចិន្ត្រៃយ៍ ផ្ទះលេខ ______ ផ្លូវ __________ ឃុំ/សង្កាត់ __________ ក្រុង/ស្រុក/ខណ្ឌ __________ រាជធានី/ខេត្ត __________ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ __________ ផុតកំណត់ ថ្ងៃទី ____ ខែ ________ ឆ្នាំ ______ សូមអះអាងថា ខ្ញុំបាទ/នាងខ្ញុំបានយល់ព្រមទទួលបំពេញមុខងារជាអ្នកបច្ចេកទេសរបស់ក្រុមហ៊ុន ______________________________ ចាប់ពីថ្ងៃទី____ ខែ______ ឆ្នាំ ______ តទៅ។

ក្នុងពេលអនុវត្តមុខងារជាអ្នកបច្ចេកទេស ខ្ញុំបាទ/នាងខ្ញុំនឹង៖

១- គោរពច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

២- គោរពបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

៣- បំពេញមុខងារស្របតាមក្រមសីលធម៌វិជ្ជាជីវៈក្នុងវិស័យសំណង់និងក្រមសីលធម៌សម្រាប់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់។

៤- មិនបំពេញមុខងារជានាយកបច្ចេកទេសឬអ្នកបច្ចេកទេសរបស់ក្រុមហ៊ុនផ្សេងទៀតឡើយ។

៥- គោរពតាមគោលការណ៍ណែនាំនិងចូលរួមវគ្គបណ្តុះបណ្តាលអំពីការអនុវត្តការងារតាមការរៀបចំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ថ្ងៃ __________ ខែ ______ ឆ្នាំ__________ ព.ស. ___

ធ្វើនៅ __________ ថ្ងៃទី_____ ខែ_______ ឆ្នាំ _______

**ហត្ថលេខានិងឈ្មោះ**

បានឃើញនិងឯកភាព

ថ្ងៃ __________ ខែ ______ ឆ្នាំ__________ ព.ស. ___

ធ្វើនៅ __________________ ថ្ងៃទី_____ ខែ_______ ឆ្នាំ _______

**ហត្ថលេខានិងឈ្មោះតំណាងនិងត្រាក្រុមហ៊ុន**

ឧបសម្ព័ន្ធទី៧នៃប្រកាសលេខ ០៣៣ ដ.ន.ស./ប្រ.ក. ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ស្តីពីបែបបទនិងបរិបថនៃការផ្តល់អាជ្ញាបណ្ណ ការផ្តល់សន្លឹកអាជ្ញាបណ្ណថ្មី ការបញ្ចប់សុពលភាព និងការបន្តសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់

គំរូទម្រង់បញ្ជីរាយនាមនាយកបច្ចេកទេសនិងអ្នកបច្ចេកទេស

**ព្រះរាជាណាចក្រកម្ពុជា**

